ភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរ លេខ ០៣ សរ**

## រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា

**សូមជំរាបមក**

អស់លោកអភិបាល ខេត្ត ក្រុង ទូទាំងប្រទេស

កម្មវត្ថុ : អំពីល្បែងស៊ីសង

មតិសាធារណៈបានកត់សំគាល់ឃើញនៅតាមទីប្រជុំជន នៃ ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ មួយចំនួនមានបើកលេងល្បែងស៊ីសងដោយចំហរ និង សម្ងាត់ តូច ធំ យ៉ាងច្រើន ហើយដែលបច្ចុប្បន្ននេះកំពុងតែរីករាលដាលជាបន្តបន្ទាប់ ពិសេសនៅរដ្ឋធានីភ្នំពេញ ដែលជាហេតុបណ្ដាលធ្វើអោយ បាត់បង់ នូវរបៀបរៀបរយ សន្តិសុខសាធារណៈ និង ជាប្រភពបង្កើតឡើងនូវអំពើចោរកម្មផ្សេង ៗ បាតុភាពនេះធ្វើអោយប្រជារាស្ត្រមានកង្វល់ក្នុងចិត្តយ៉ាងខ្លាំងអំពីសន្តិសុខក្នុងគ្រួសារ និង បុគ្គលម្នាក់ ៗ ដែល ទាមទារត្រូវតែដោះស្រាយ ហាមឃាត់អំពើទាំងនេះមិនអោយមានក្នុងសង្គមជាតិជាបន្ទាន់ ដើម្បីរក្សា ភាពសុខដុមរមនាជូនប្រជារាស្ត្រយើង ។

ស្ថិតចំពោះមុខសភាពការណ៍ខាងលើនេះ រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា ចេញបញ្ជា អោយអភិបាលខេត្ត ក្រុង ទូទាំងប្រទេស ចាត់វិធានការណ៍ដ៏មានប្រសិទ្ធភាពបំផុតក្នុងការទប់ស្កាត់ និង ហាមឃាត់រាល់ល្បែងស៊ីសងគ្រប់ប្រភេទទាំងអស់ ។

ទទួលបានសារាចរនេះ អភិបាលខេត្ត ក្រុង ត្រូវចាត់តាំងអនុវត្ត ហើយត្រូវរាយការណ៍មកក្រសួងមហាផ្ទៃ នៅដំណាច់ខែ កក្កដា ឆ្នាំ ១៩៩៣ អំពីលទ្ធផលដែលសំរេចបានក្នុងបញ្ហាខាងលើ ។

សហប្រធាន

នៃរដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា

ព្រះហស្តលេខា　　　　ហត្ថលេខា

ស្ដេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ**　　　　**ហ៊ុន សែន**